ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ១០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែតុលា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកញ្ញា ឆ្នាំ២០១៣ | ៣ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ៩ |

## សេចក្តីព្រាងច្បាប់ស្តីពី

# ការបង្កើតក្រសួងមុខងារសាធារណៈ

កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ហុង ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)និង ឯកឧត្តម **ឡាំ ជា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត**ក្រសួងមុខងារសាធារណៈ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

រដ្ឋលេខាធិការមុខងារសាធារណៈបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ ក្នុងគោលបំណងចូលរួមអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ក្របខណ្ឌ័យុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គោលនយោបាយស្តីពីសេវាសាធារណៈ និងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ទាមទារឲ្យមានការប្រែប្រួលនូវយន្តការគ្រប់គ្រងក្នុងវិស័យមុខងារសាធារណៈនៅកម្ពុជា។

សារតារនៃការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសារណៈមានដូចខាងក្រោម៖

ចាប់តាំងពីឆ្នាំ១៩៩៦ វិស័យមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានដឹកនាំនិងគ្រប់គ្រងដោយអង្គការរដ្ឋមួយដែលបង្កើតកម្រិតត្រឹមរដ្ឋលេខាធិការដ្ឋាន យោងតាមព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។



ដោយឈរលើចក្ខុវិស័យវែងឆ្ងាយរបស់ប្រមុខរាជរដ្ឋាភិបាល លោកបានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ឲ្យរៀបចំអង្គការរដ្ឋមួយនេះដំឡើងទៅជាក្រសួង។

សេចក្តីព្រាងច្បាប់នេះត្រូវបានក្រុមការងាររៀបចំឡើងដោយផ្អែកលើសារាចរលេខ០៣ ស.រ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការអនុវត្តគោលការណ៍ណែនាំអំពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

សេចក្តីព្រាងច្បាប់នេះមានចំនួន ៦មាត្រា ដែលមានខ្លឹមសារកំណត់អំពីការបង្កើតសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងអ្នកដឹកនាំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ស្ថាប័ននេះ ខ្លឹមសារនិរាករណ៍បទបញ្ញត្តិដែលផ្ទុយ និងការប្រកាសឲ្យប្រើជាការប្រញាប់[(១)]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងច្បាប់នេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកញ្ញា ឆ្នាំ២០១៣*



របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកញ្ញា ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលដឹកនាំដោយឯកឧត្ដម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➡ នាខែកញ្ញាឆ្នាំ២០១៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,៧% ធៀបនឹងខែមុន និងកើនឡើង៣,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។ ក្នុងនោះ ម្ហូបអាហារ សម្លៀកបំពាក់និងស្បែកជើង សុខាភិបាលការកម្សាន្តនិងវប្បធម៌ ការសិក្សា និងភោជនីយដ្ឋាន ជាក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនកើនលើសពីអត្រាមធ្យម។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុនក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | | |
|---|---|---|---|
| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
| ម្ហូបអាហារ: +៥,៣%<br>សម្លៀកបំពាក់និងស្បែកជើង: +៥,៤%<br>គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់:+៣,៧%<br>សុខាភិបាល: +៩,៤% | ការដឹកជញ្ជូន: −១,៣%<br>ការកម្សាន្តនិងវប្បធម៌ : +៦,៦%<br>ការសិក្សា : +៧,៦%<br>ភោជនីយដ្ឋាន:+៦,៧% | សាច់គោស្រស់: +៩,៤%<br>សាច់មាន់ស្រស់:+៧,២%<br>ត្រីស្រស់:+៣,១%<br>ផ្លែឈើ:+៧,៧% | បន្លែ: +១០%<br>ឧស្ម័ន: -២,៨%<br>ប្រេងសាំង: -៥,៣%<br>ប្រេងម៉ាស៊ូត:-១,៥% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១-២០១៣

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា[P] | វិច្ឆិកា[P] | ធ្នូ[P] | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៧% | ៣,៨% | ៤,០% | ៤,២% | ២,៩% |
| | ខែមុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧ | -០,២% | ០ | ០,២ | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | ខែមុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,២% | ០ | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |

P: តួលេខខែ តុលា វិច្ឆិកា ធ្នូ និងប្រចាំឆ្នាំ២០១៣ ជាតួលេខព្យាករដោយ ក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

ក្រាហ្វ ១.សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន(ឆ្នាំ២០១១ ២០១២ និង២០១៣)







➡អត្រាប្តូរប្រាក់៖

| ប្រភេទ | កញ្ញា២០១៣ | សីហា២០១៣ | កញ្ញា២០១២ | ប្រភេទ | កញ្ញា២០១៣ | សីហា២០១៣ | កញ្ញា២០១២ |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៤០៦២រ/១$ | ៤០៦២រ/១$ | ៤០៤៣រ/១$ | បាត/ដុល្លារ | ៣២,១៣បាត/១$ | ៣២,១៣បាត/១$ | ៣០,៨៦បាត/១$ |
| រ/បាត | ១២៩រ/១បាត | ១២៦រ/១បាត | ១៣១រ/១បាត | ដុង/ដុល្លារ | ២១១១២ដុង/១$ | ២១១២០ដុង/១$ | ២០៨៦០ដុង/១$ |
| រ/ដុង | ០,១៩២រ/១ដុង | ០,១៩២រ/១ដុង | ០,១៩៣រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែកញ្ញាឆ្នាំ ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១.ចំណូលថវិកាជាតិ** : អនុវត្តបាន ៦៤០,៥ពាន់លានរៀល(មធ្យមប្រចាំខែ ៦៩% នៃគម្រោង)ក្នុងនោះចំណូលចរន្ត ៦៤០,៥ពាន់លានរៀល (មធ្យមប្រចាំខែ ៩៦% នៃគម្រោង)និងពុំមានចំណូលមូលធនទេ។

ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ — ២០១៣
(ពាន់លានរៀល)




➢បើធៀបនឹងខែមុនចំណូលថវិកាជាតិ ថយចុះ ៦% ប៉ុន្តែកើនឡើង ៦,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណូលចរន្តថយចុះ១%ធៀបនឹងខែមុនប៉ុន្តែកើនឡើង៩%*ធៀបនឹងខែដូចគ្នាឆ្នាំមុន*។

➢ក្នុងចំណូលចរន្ត៖

✓ចំណូលសារពើពន្ធមានចំនួន ៥៧៨,៥ពាន់លានរៀលកើនឡើង៨%ធៀបនឹងខែមុននិងកើនឡើង១៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៦១,៩ពាន់លានរៀល ថយចុះ ៤៤% ធៀបនឹងខែមុន និងថយចុះ ៣៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ :-៥% | (-១%) | ➢ នេសាទ :+៥៨% | (+១០០%) |
| ➢ ចំណូលពន្ធដារ : +៤% | (+២៦%) | ➢ រុក្ខាប្រមាញ់ : -៩% | (+៧៦៥%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ :+៤% | (-៤%) | ➢សម្បទានរ៉ែ : -៤៨% | (-៣២%) |
| ✧ កាស៊ីណូ :+៨% | (-១៤%) | ➢ អាកាសចរណ៍ស៊ីវិល :-៩២% | (-២៣%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក :-៦៧% | (-៧៩%) | ➢ ផលទុននៃសកម្មភាពទេសចរណ៍ :+៣៩% | (កើនគំហុក) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :+៥% | (+៩%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍ :-៤៦% | (-២%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ) :-៥៣% | +៦% |

**២.២.** ***ចំណាយថវិកាជាតិ៖*** អនុវត្តបានចំនួន៥៨០ពាន់លានរៀល(*មធ្យមប្រចាំខែ ៥៣% នៃគម្រោង*) ក្នុងនោះចំណាយចរន្តមានចំនួន ៤៥៦ពាន់លានរៀល (*មធ្យមប្រចាំខែ ៧៣% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ១២៤ពាន់លានរៀល។

➢*បើធៀបនឹងខែមុន*ចំណាយថវិកាជាតិកើនឡើង ៥% និងកើនឡើង ៣៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង ១២% ធៀបនឹងខែមុន និងកើនឡើង ៣៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯចំណាយមូលធន ថយចុះ ១៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢*ថវិកាជាតិនៃខែកញ្ញាមានអតិរេក ៦១ពាន់លានរៀលស្មើនឹង ១៥,២លានដុល្លារ ស.រ.អា។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកញ្ញា ឆ្នាំ២០១៣មានលក្ខណៈដូចខាងក្រោម :

➢រូបិយវត្ថុ$M_2$ មានចំនួន ២៩៣៥៦ពាន់លានរៀល កើនឡើង ០,៧% ធៀបនឹងខែមុន និងកើនឡើង៩,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ការកើនឡើងនៃ$M_2$ ធៀបនឹងខែមុន ជាចម្បងបណ្ដាលមកពីរូបិយវត្ថុក្រៅធនាគារ កើនឡើង ២,១% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំកើនឡើង ៩,៨% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ០,៥%។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៩,២% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨០,៨%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុខែកញ្ញា ឆ្នាំ២០១៣




| សមាមាត្រចំនួនប្រាក់រៀល ក្នុងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,២% | ១៧,៣% | ១៧,០% | ១៧,៣% | ១៦,៩% | ១៦,៨% | ១៨,១% | ១៩% | ១៩,២ | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៧% | ១៣,៧% | ១៣,៩% | **១៤,០%** | ១៣,៣% | ១៣,៤% | ១៤,៣% | ១៤,៥% | ១៤,៧ | | | |

បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែកញ្ញា២០១៣: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធមានចំនួន ៣៤១៤ លានដុល្លារកើនឡើង 0,២% ធៀបនឹងខែមុន និងកើនឡើង ៣,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* ក្នុងខែនេះមានចំនួន ៧៤៩៤ពាន់លានរៀលថយចុះ 0,៤% ធៀបនឹងខែមុន និងថយចុះ ១៧,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢*ការផ្តល់ឥណទាន៖*

| *ផ្តល់ដោយ* | *កញ្ញា ២០១៣* | *សីហា ២០១៣* | *កញ្ញា ២០១២* |
|---|---|---|---|
| ធនាគារពាណិជ្ជ(ពាន់លានរៀល)<br>ក្នុងនោះ ជារៀល | ២៨២៥៧ | ២៧៦៦៦<br>៤៦៨ | ២១៤១២<br>៣៨៨ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | | ៤៥៤៥ | ៣២៥៣ |

➢***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែកញ្ញា៖

| *ប្រភេទអត្រាការប្រាក់* | *កញ្ញា២០១៣* | *សីហា២០១៣* | *កញ្ញា២០១២* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៤% | ៥,៩៤% | ៥,៩១% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៩៣% | ១១,៩៣% | ១១,៨១% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៨% | ៤,៣៩% | ៤,៤៤% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៣០% | ១១,៣៧% | ១១,៩៧% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកញ្ញាឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម៖**

✓ផលិតផលនេសាទមាន ៤៥ពាន់តោនកើនឡើង ១0% ធៀបនឹងខែមុន និងកើនឡើង ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម៖**

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣៣៧,១GWh កើនឡើង ៣% ធៀបនឹងខែមុន និងកើនឡើង ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះវារីអគ្គិសនីមានចំនួន ១៩0,៩ GWh កើនឡើង ៨% ធៀបនឹងខែមុន និងកើនឡើង ៣៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤៧៧,៦ លានដុល្លារ ថយចុះ ១% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ១៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជីរោងចក្រឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន—កញ្ញា២០១៣ | ចំនួន—សីហា២០១៣ | ចំនួន—កញ្ញា២០១២ |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | ២៣ | ១៨ | ៣០ |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១០៥២ | ១០២៩ | ៨៤៧ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២២ | ២៧ | ០ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៨ | ៨ | ០ |

➤**សំណង់** (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៧០,២ពាន់ម² ថយចុះ ០,៤% ធៀបនឹងខែមុន និងថយចុះ ៥៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។បើគិតជាសាច់ប្រាក់ស្មើនឹង ១៣០,៩លានដុល្លារ កើនឡើង ៣១% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៥៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម²—កញ្ញា២០១៣ | ពាន់ម²—សីហា២០១៣ | ពាន់ម²—កញ្ញា ២០១២ |
|---|---|---|---|
| ▪ លំនៅឋាន | ១៣៦,៩ | ១៣៧,០ | ១៧០ |
| ▪ ឧស្សាហកម្ម | ២៥,១ | ១៨៥,៧ | ១២២,៦ |
| ▪ ផ្សេងៗ | ១៨៦,០ | ២៥,២ | ១៥,០ |
| អនុញ្ញាតសរុប | ៣៧០,២ | ៣៧១,៨ | ៨១០,៤ |

✓ ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅឋាន៣៧% និងផ្សេងៗ ៥០% នៃផ្ទៃក្រឡាសរុប។

➤**ការងារ៖**

| ប្រភេទ | នាក់ : កញ្ញា២០១៣ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១១៩០ | +២៦% | -៧០% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣២៦២ | +១១១% | -៥២% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៦៣៣ | +៧២% | -៤៧% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៦២៩ | +១៧៥% | -៥៧% |

➤**វិនិយោគ៖**

✓គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក. និង គ.ស.ព. (ថ្មីនិងពង្រីក)៖

| ប្រភេទ | កញ្ញា២០១៣ | សីហា២០១៣ | កញ្ញា២០១២ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១១៨ | ៣៨៣ | ៦៣,៩ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៥១ | ២,៧ | ៥,២ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៦៧(១៧) | ១២០,៣ (០) | ៥៨,៧ (៧,៦) |
| វិស័យទេសចរណ៍ | ០ | ២៥៩,៩ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៣ | ១៥ | ១០ |
| បង្កើតការងារ (ពាន់នាក់) | ១៩ | ១៤,៣ | ១១,១ |

➤**សេវាកម្ម និងទេសចរណ៍៖**

✓ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—កញ្ញា២០១៣ | ចំនួន—សីហា២០១៣ | ចំនួន—កញ្ញា២០១២ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៧១ | ២៦៤ | ៣០៦ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ | ៥ | ៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៣០៥ | ៣០១ | ១៦៣ |

✓**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប ៥កំពង់ផែ) មានចំនួន ៤៧២,៩ពាន់តោន ថយចុះ៣៣% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង ១៩% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

| ក្នុងវង់ក្រចក : បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ :-២២% | (-២៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង :-៣៣% | (+២៦៥%) |
| ▪ កំពង់ផែកំពង់សោម :-៣១% | (+១៣%) | ▪ កំពង់ផែឧកញ៉ាម៉ុង :-៤៩% | (+១៧%) |

➢**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៥ | -៣៤% | +២០% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៣,៧ | -១៩% | -១៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៩៦,៥ | -១៧% | +១៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៦ | -៥% | 0% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ២៨៤ | -១៧% | +១៧% |
| ✓ តាមផ្លូវអាកាស | ១២៩ | -១៦% | +២០% |
| ✓ តាមផ្លូវគោក និងទឹក | ១៥៤ | -១៨% | +១៥% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលខែកញ្ញា មានចំនួន ២៨៧៤ពាន់លានរៀល (៧១៨,៤លានដុល្លារ) ថយចុះ ១០% ធៀបនឹងខែមុន និងថយចុះ ៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៥% | -៣% | រថយន្តសរុប (ព.ល.រ) | +៨% | +១១% |
| ប្រេងម៉ាស៊ូត | -២៤% | +១% | រថយន្តសរុប (គ្រឿង) | +១១% | -៩% |
| ឧស្ម័ន | -២៩% | +៣% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -១១% | -២០% |
| អគ្គិសនីនាំចូល | -១២% | -១៤% | ម៉ូតូ (គ្រឿង) | -២៨% | -៤០% |
| ដែកសំណង់ | +១% | -៣៥% | អង្ករ | -៥៤% | -៦៦% |
| ស៊ីម៉ង់ត៍ | -២៥% | -៧% | ផ្លែឈើនិងបន្លែ | -១២% | -៥% |
| គ្រឿងអេឡិចត្រូនិក | -៤% | -២៦% | ជីនិងថ្នាំកសិកម្ម | +៥% | +៩% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | -១២% | +៤% |

➡ **ការនាំចេញ**ខែកញ្ញា ឆ្នាំ២០១៣ មានចំនួន ២៤២៦ពាន់លានរៀល ស្មើនឹង ៦០៦,៥លានដុល្លារ ស.រ.អា. (៨៤% នៃការនាំចូល) ថយចុះ ២១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ មុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +៣៣% | +៦៣% | ផលិតផលនេសាទ | -៥៣% | -៧៤% |
| វាយនភណ្ឌនិងស្បែកជើង | -២៥% | +១២% | កៅស៊ូ | -២៥% | -៦% |
| អង្ករ | -៥% | +១១៩% | | | |

➡ក្នុងខែកញ្ញានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន៤៤៧ពាន់លានរៀល ស្មើនឹង ១១២លានដុល្លារ ស.រ.អា.។

### ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកញ្ញា ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| លរ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | –៦៧% | –៧៩% | ជាប្រភេទចំណូលសារពើពន្ធផ្សេងៗ |
| ២ | អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនី | ៨%+ | ៣៩%+ | ការផ្គត់ផ្គង់វារីអគ្គិសនីនាពេលបច្ចុប្បន្ន មានចំនួន ជាង៥០ %នៃការផ្គត់ផ្គង់អគ្គិសនីសរុប |
| ៣ | សំណង់អនុញ្ញាតឲ្យសាងសង់ | –០៤%, | –៥៤% | — |

### ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១. **ស្ថានភាពថ្លៃ៖** ការឡើងថ្លៃគួរឲ្យកត់សម្គាល់នៃទំនិញ ក្រុមសុខាភិបាល និងការសិក្សា។ បើប្រៀបធៀបខែកញ្ញាដូចគ្នា ឆ្នាំ២០១៣ និង ២០១២ ក្រុមសុខាភិបាលឡើងថ្លៃ ៩៤,% ដែលជាចម្បង ផ្អែកទៅលើថ្លៃសេវាស្នាក់នៅ ថ្នាំ និងបរិក្ខារពេទ្យ រីឯក្រុមការសិក្សាឡើងថ្លៃ ៧៦,%។

២. **ស្ថានភាពរូបិយវត្ថុ៖** សម្រាប់លក្ខខណ្ឌបច្ចុប្បន្ននៃសេដ្ឋកិច្ចកម្ពុជា ប្រាក់រៀលនៅក្រៅធនាគារមានចំនួនមិនទាន់គ្រប់គ្រាន់ ក្នុងន័យការជំរុញការប្រើប្រាស់ប្រាក់រៀល តម្រូវការលើប្រាក់រៀល និងក្នុងទិសដៅស្ថេរភាពអត្រាប្តូរប្រាក់។

៣. **ថាមពល៖** មានការកើនឡើងនូវផលិតកម្មក្នុងស្រុកនៃវារីអគ្គិសនីគួរឲ្យកត់សម្គាល់។

៤. **ការនាំចូល៖** តួលេខការនាំចូលអង្ករមានកម្រិតខ្ពស់ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ២០១២ និង២០១៣នេះ។

*សេចក្តីសន្និដ្ឋាន៖*

១. គោលនយោបាយរូបិយវត្ថុកម្ពុជាគួរមានទិសដៅធ្វើបដិដុល្លារូបនីយកម្មជាជំហានៗ។ ដូច្នេះការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជារៀងរាល់ឆ្នាំ ជាយុទ្ធសាស្ត្រដើម្បីសម្រេចបានទិសដៅនេះ។ ធនាគារជាតិគួររក្សាសមាមាត្រនៃសាច់ប្រាក់រៀលក្រៅធនាគារ ធៀបនឹង M2 ឲ្យមានការកើនឡើងជាបណ្តើរៗ។

២. ថាមពលអគ្គិសនីជាធាតុចូលមួយយ៉ាងសំខាន់ នៅក្នុងផលិតកម្មទំនិញ និងសេវា។ ដូច្នេះ គួរពិចារណាអំពីការបញ្ចុះ ថ្លៃអគ្គិសនីតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនៃផលិតកម្មជាតិជាមួយប្រទេសជិតខាង ក៏ដូចជា ការទាក់ទាញវិនិយោគបរទេស។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម ឃឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១០/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមបើកកិច្ចប្រជុំជំនាញបច្ចេកទេស លើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមការជក់ និងការបង្អួយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៨/១០/១៣<br>ពេញមួយថ្ងៃ | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១០/១០/១៣<br>ម៉ោង ១៦ : ០០នាទី | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីក្រុងពាលី អភិសេក សម្ពោធឆ្លងព្រះបរមរូបព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសួនច្បារ ខាងកើតវិមានឯករាជ្យ។ |
| ៤ | ១១/១០/១៣<br>ម៉ោង ០៧: ៣០នាទី | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធវិមានព្រះបរមរូប ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅសួនច្បារខាងកើតវិមានឯករាជ្យ។ |
| ៥ | ១១/១០/១៣<br>ម៉ោង ១៥: ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីការអនុវត្តគម្រោងសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរស៊ីវិល ដែលជាជំនួយរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ តាមរយៈ KOI CA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៤/១០/១៣<br>ម៉ោង ១៥ :៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ។<br>២-សេចក្តីព្រាងរបាយការណ៍តាមកាលកំណត់ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវជនបទ។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ១៥/១០/១៣<br>ម៉ោង ០៧:១៥នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីដាក់កូរោនផ្កា គោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ គម្រប់ខួប ០១ឆ្នាំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅវិមានព្រះបរមរូប (សួនច្បារវិមានឯករាជ្យ)។ |
| ៨ | ១៦/១០/១៣<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៣ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៦/១០/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យ នៅជាប់របងជុំវិញ បរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៧/១០/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ។<br>២-សេចក្ដីព្រាងរបាយការណ៍តាមកាលកំណត់ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។<br>៣-សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ការដឹកនាំការត្រួត ពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្ដាញផ្លូវជនបទ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៧/១០/១៣<br>ម៉ោង ១៥:០០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១២ | ២០/១០/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមប្រជុំការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** ។ |
| ១៣ | ២១/១០/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-បញ្ហាផ្សេងៗ៖<br>៣-១-សំណើសុំសិទ្ធិប្រទាន ដើម្បីផ្ដល់សច្ចាប័នលើលិខិតគូបករណ៍ នៃសោធនកម្មធម្មនុញ្ញ របស់អង្គការអន្តរជាតិ ខាងការងារ (ILO) ឆ្នាំ១៩៨៦។<br>៣-២-កិច្ចព្រមព្រៀងអាស៊ានស្ដីពីបំលាស់ទីរូបវន្តបុគ្គល។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | ២២/១០/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-បញ្ហាផ្សេងៗ៖<br>៣-១-សំណើសុំសិទ្ធិប្រទាន ដើម្បីផ្ដល់សច្ចាប័នលើលិខិតតូបករណ៍ នៃសោធនកម្មធម្មនុញ្ញ របស់អង្គការអន្តរជាតិខាងការងារ (ILO) ឆ្នាំ១៩៨៦។<br>៣-២-កិច្ចព្រមព្រៀងអាស៊ានស្ដីពីបំលាស់ទីរូបវន្តបុគ្គល។<br>នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២២/១០/១៣<br>ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ៅ សុវណ្ណា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៤/១០/១៣<br>ម៉ោង ១៦ : ០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួល និងសហការជាមួយភាគីចិន លើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២៤/១០/១៣<br>ម៉ោង ១៨:០០នាទី | ជួបប្រជុំជាមួយ ឯកឧត្តម យឹម ណុលសន ដើម្បីពិភាក្សាលើ៖<br>១-គម្រោងវិនិយោគសាងសង់ខ្សែបណ្ដាញបញ្ជូនអគ្គិសនី២៣០គីឡូវ៉ុល តភ្ជាប់ភ្នំពេញ-ព្រះសីហនុ។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | ២៥/១០/១៣<br>ពេញមួយថ្ងៃ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។<br>៣-គម្រោងវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី២៣០គីឡូវ៉ុល តភ្ជាប់ភ្នំពេញ-ព្រះសីហនុ។<br>៤-សេចក្តីព្រាងរបាយការណ៍ស្តីពីការត្រួតពិនិត្យឡើងវិញតាមកាលកំណត់ជាសកលស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។<br>៥-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវជនបទ។<br>៦-បញ្ហាផ្សេងៗ៖សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៦-១-ពិធីសារ និងពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ។<br>៦-២-ពិធីសារទី៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន និងពិធីសារបូមបញ្ចូលវិធានការអនាម័យ និងភូតគាមអនាម័យនិងរបាំងបច្ចេកទេសពាណិជ្ជកម្មទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។<br>៦-៣-ពិធីសារដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួនដែលពាក់ព័ន្ធពាណិជ្ជកម្មទំនិញ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងៗទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០/១០/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីក្រុងពាលី អភិសេក សម្តេចឆ្លងព្រះបរមរូប ព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភា ចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសួនច្បារ ខាងកើត វិមានឯករាជ្យ។ |
| ២ | ១១/១០/១៣<br>ម៉ោង ១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីការអនុវត្តគម្រោងសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរស៊ីវិល ដែលជាជំនួយរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ តាមរយៈ KOICA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៧/១០/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ។<br>២-សេចក្តីព្រាងរបាយការណ៍តាមកាលកំណត់ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវជនបទ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២២/១០/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-បញ្ហាផ្សេងៗ៖<br>៣-១-សំណើសុំសិទ្ធិប្រទាន ដើម្បីផ្តល់សច្ចាប័នលើលិខិតតូបករណ៍ នៃសោធនកម្មធម្មនុញ្ញ របស់អង្គការ អន្តរជាតិ ខាងការងារ (ILO) ឆ្នាំ១៩៨៦។<br>៣-២-កិច្ចព្រមព្រៀងអាស៊ានស្តីពីចំលាស់ទីរូបវន្តបុគ្គល។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣

## ឯកឧត្តម ឌុយ ធៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០/១០/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីក្រុងពាលី អភិសេក សម្ពោធឆ្លងព្រះបរមរូប ព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភា ចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសួនច្បារ ខាងកើត វិមានឯករាជ្យ។ |
| ២ | ១១/១០/១៣<br>ម៉ោង ១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីការអនុវត្តគម្រោងសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរស៊ីវិល ដែលជាជំនួយរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ តាមរយៈ KOICA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៧/១០/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ។<br>២-សេចក្តីព្រាងរបាយការណ៍តាមកាលកំណត់ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវជនបទ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២២/១០/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-បញ្ហាផ្សេងៗ÷<br>៣-១-សំណើសុំសិទ្ធិប្រទាន ដើម្បីផ្តល់សច្ចាប័នលើលិខិតតូបករណ៍ នៃសោធនកម្មធម្មនុញ្ញ របស់អង្គការ អន្តរជាតិ ខាងការងារ (ILO) ឆ្នាំ១៩៨៦។<br>៣-២-កិច្ចព្រមព្រៀងអាស៊ានស្តីពីបំលាស់ទីរូបវន្តបុគ្គល។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣

**ឯកឧត្តម ម៉ាន់ គិរុណា អគ្គលេខាធិការ**

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០/១០/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីក្រុងពាលី អភិសេក សម្ពោធឆ្លងព្រះបរមរូប ព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភា ចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសួនច្បារ ខាងកើត វិមានឯករាជ្យ។ |
| ២ | ១១/១០/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីការអនុវត្តគម្រោងសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលអាកាសចរស៊ីវិល ដែលជាជំនួយរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ តាមរយៈ KOICA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៧/១០/១៣ ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ។<br>២-សេចក្តីព្រាងរបាយការណ៍តាមកាលកំណត់ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវជនបទ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២២/១០/១៣ ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-បញ្ហាផ្សេងៗៈ<br>៣-១-សំណើសុំសិទ្ធិប្រទាន ដើម្បីផ្តល់សច្ចាប័នលើលិខិតតូបករណ៍ នៃសោធនកម្មធម្មនុញ្ញ របស់អង្គការ អន្តរជាតិ ខាងការងារ (ILO) ឆ្នាំ១៩៨៦។<br>៣-២-កិច្ចព្រមព្រៀងអាស៊ានស្តីពីបំលាស់ទីរូបវន្តបុគ្គល។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងៗទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៣

## ឯកឧត្តម ម៉ាន់ ធិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៥ | ២៥/១០/១៣<br>ពេញមួយថ្ងៃ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។<br>៣-គម្រោងវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី២៣០គីឡូវ៉ុល តភ្ជាប់ភ្នំពេញ-ព្រះសីហនុ។<br>៤-សេចក្តីព្រាងរបាយការណ៍ស្តីពីការត្រួតពិនិត្យឡើងវិញតាមកាលកំណត់ជាសកលស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។<br>៥-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួត ពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវជនបទ។<br>៦-បញ្ហាផ្សេងៗ៖សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៦-១-ពិធីសារ និងពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោម ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ។<br>៦-២-ពិធីសារទី៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាង សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន និងពិធីសាររួមបញ្ចូល វិធានការអនាម័យ និងភូតគាមអនាម័យនិងរបាំងបច្ចេកទេសពាណិជ្ជកម្មទៅក្នុងកិច្ចព្រម ព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។<br>៦-៣-ពិធីសារដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួនដែលពាក់ព័ន្ធ ពាណិជ្ជកម្មទំនិញ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

# សិក្ខាសាលាស្តីពីការបញ្ជ្រៀបការយល់ដឹងជាសាធារណៈ ចំពោះការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការជួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ADB បានរៀបចំ សិក្ខាសាលស្តីពីការបញ្ជ្រៀបការយល់ដឹងជាសាធារណៈចំពោះការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) នៅសកលវិទ្យាល័យន័រតុន កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជានាយកគម្រោង RIA ។

ធនាគារអភិវឌ្ឍន៍អាស៊ី ADB រួមជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបង្កើតគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅកាត់ថា RIA។ ការបង្កើតគម្រោង RIA ក្នុងបំណងពង្រឹងការធ្វើកំណែទម្រង់បញ្ញត្តិកម្ម សម្រេចបានឲ្យនូវវប្បធម៌បង្កើតគោលនយោបាយ និងអភិបាលកិច្ចកាន់តែប្រសើរ តាមរយៈការដាក់ឲ្យអនុវត្តប្រព័ន្ធវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត ពោលជំរុញឲ្យមានការវាយតម្លៃ និងសិក្សាឲ្យបានល្អិតល្អន់បំផុតមុនចេញលិខិតបទដ្ឋានគតិយុត្ត និងបញ្ញត្តិកម្ម ធ្វើយ៉ាងណាកាត់បន្ថយផលប៉ះពាល់ជាអតិបរមានៅក្នុងសង្គម។



ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរងនិងជាអ្នកគ្រប់គ្រងគម្រោង RIA បានថ្លែងឲ្យដឹងក្នុងឱកាសបើកសិក្ខាសាលាផ្សព្វផ្សាយគម្រោងដល់និស្សិតសាកលវិទ្យាល័យន័រតុន ថាការបង្កើតគម្រោង RIA ដើម្បីជំរុញពិពិធកម្មសេដ្ឋកិច្ច ដែលបង្កើតឡើងតាមរយៈកំណែទម្រង់ ដោយបង្កើនការយកចិត្តទុកដាក់ លើកំណែទម្រង់បញ្ញត្តិកម្ម និងគោលនយោបាយប្រកួតប្រជែង។ វាគឺជាការពង្រីក និងធ្វើពិពិធកម្មវិស័យឯកជនតាមរយៈការលើកកម្ពស់បរិយាកាសធុរកិច្ច។ ការដាក់ឲ្យអនុវត្តយន្តការ RIA នៅតាមក្រសួង-ស្ថាប័ន ជាការចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ (ដំណាក់កាលទី៣) របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាព។

ឯកឧត្តម **ម៉ិច សុខា** បានឲ្យដឹងដែរថា គម្រោង RIA គឺជាការប្រៀបធៀបពីបន្ទុកចំណាយ និងផលចំណេញ និងជាការវាយតម្លៃយ៉ាងលម្អិតពីផលចំណេញ និង ផលប៉ះពាល់ដល់អ្នកពាក់ព័ន្ធទាំងអស់ ក្រោយពីក្រសួងចេញសេចក្តីប្រកាស ឬបញ្ញត្តិកម្មអ្វីមួយ។

ឯកឧត្តម បានគូសបញ្ជាក់ថា «រាល់របាយការណ៍ RIA ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេចមុនចុះហត្ថលេខាលើសំណើបញ្ញត្តិកម្ម។ គ្រប់ក្រសួងស្ថាប័ន ត្រូវរៀបចំសំណើបញ្ញត្តិកម្ម ហើយត្រូវសិក្សា និងវិភាគឲ្យបានស៊ីជម្រៅ ពីផលប៉ះពាល់ផ្សេងៗ។ យើងគិតថា តើបន្ទុកបញ្ញត្តិកម្ម នៅពេលយើងដាក់បញ្ញត្តិកម្មមួយ ប្រជាជន ឬអ្នកប្រកបរបរផ្សេងៗ គាត់រងបន្ទុកអីគេខ្លះ?»។

គម្រោង RIA បាននិងកំពុងអនុវត្តយ៉ាងសកម្មនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ជឿនលឿនដូចជា អូស្ត្រាលី និងអង់គ្លេស និងបណ្តាប្រទេសជាច្រើនទៀត នៅលើសកលលោក ហើយគម្រោងនេះ ក៏បានជំរុញឲ្យបណ្តាប្រទេសនោះ ទទួលបានជោគជ័យខ្ពស់ក្នុងការជំរុញ កិច្ចអភិវឌ្ឍប្រទេសឲ្យបានកាន់តែរីកចម្រើន។ ក្នុងនោះប្រទេសតំបន់អាស៊ី ក្រោមការជំរុញពីធនាគារ ADB គម្រោង RIA បាននិងកំពុងដំណើរការនៅក្នុងប្រទេសហ្វិលីពិន វៀតណាម ឡាវ រួមនឹងកម្ពុជាផងដែរ។ បើតាមឯកឧត្តម **ម៉ិច សុខា** គម្រោង RIA ត្រូវបានបង្កើតឡើងនៅកម្ពុជាក្រោមជំនួយឥតសំណងរបស់ ADB ហើយ ចាប់ផ្តើមអនុវត្តគម្រោង RIA នៅខែតុលា ឆ្នាំ២០១១ បន្ទាប់ពីមានបេសកម្មពិនិត្យស្ថានភាពជាក់ស្តែង និងសកម្ម ភាពផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងនៅឆ្នាំ២០០៩។



ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងជានាយកគម្រោងវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត បានថ្លែងថា ការធ្វើបញ្ញត្តិកម្មមានសារសំខាន់ណាស់ និងចាំបាច់សម្រាប់សង្គមនីមួយៗ ដើម្បីគ្រប់គ្រងសង្គមឲ្យចម្រើន និងប្រសើរឡើង តែវាក៏នាំមកនូវផលប៉ះពាល់ផងដែរ តែរាជរដ្ឋាភិបាលក៏ត្រូវតែប្រុងប្រយ័ត្នធ្វើកុំឲ្យបញ្ញត្តិកម្មទាំងនោះមានផលអវិជ្ជមានមិនចាំបាច់ដល់អ្នកប្រតិបត្តិតាម។ «RIA ទាមទារឲ្យក្រសួងត្រូវអនុវត្តគោលការណ៍ប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អក្នុងការរៀបចំ សំណើលិខិតបទដ្ឋានគតិយុត្ត និងវាយតម្លៃឲ្យបានល្អិតល្អន់លើបញ្ញត្តិកម្មណាមានផលប៉ះពាល់ដល់ធុរកិច្ច»។ បើតាមឯកឧត្តម **ឃឹម ណុលសន** គម្រោង RIA នេះ មិនងាយស្រួលឡើយ សម្រាប់ការអនុវត្តនៅកម្ពុជា និយាយពីទ្រឹស្តីនៃការអនុវត្តវិធីសាស្ត្រ RIA ជាការងាយស្រួល តែការអនុវត្តជាក់ស្តែងមានការលំបាកច្រើនដូចជា ការធ្វើការពិគ្រោះយោបល់ឲ្យមានគុណភាពនិងប្រសិទ្ធិភាព ការគណនាបន្ទុកចំណាយនិងផលចំណេញជាដើម។

ឯកឧត្តម បញ្ជាក់ថា «អ្វីដែលគម្រោង RIA កំពុងអនុវត្តនេះ គឺជាទស្សនៈថ្មី ជាទម្លាប់ថ្មី ជាឥរិយាបទថ្មី ក្នុងការរៀបចំ សំណើលិខិតបទដ្ឋានគតិយុត្ត ដែលក្រសួងនិមួយៗមិនធ្លាប់ធ្វើពីមុនមក ទៅតាមទម្រង់ថ្មីនេះ តែយើងសង្ឃឹមថា បើយើងទម្លាប់ចាប់ប្រតិបត្តិយូរបន្តិចទៅ ដូចយើងរៀនមុខវិជ្ជាថ្មីដែរ ធ្វើលំហាត់ច្រើនទៅ យើងក៏យល់បានច្រើន ហើយវានឹងទៅជាការងាយស្រួលទៅវិញ»។ ឯកឧត្តម **ឃឹម ណុលសន** ក៏បាន ថ្លែងឲ្យដឹងដែរថា គម្រោង RIA ត្រូវបានផ្សព្វផ្សាយជាបន្ត បន្ទាប់ទៅតាមក្រសួង ចំនួន១៩ ហើយក៏ទទួល បានការគាំទ្រជាច្រើនផងដែរ។ ក្រៅពីការផ្សព្វផ្សាយតាមបណ្តាក្រសួងគម្រោង RIA ក៏ ត្រូវបានផ្សព្វផ្សាយ នៅតាមសាកលវិទ្យាល័យរដ្ឋ និងឯកជនជាច្រើនទៀត ដើម្បីជំរុញឲ្យ និស្សិតស្វែងយល់ និងជាមូលដ្ឋាន សម្រាប់ធ្វើការវង្វាយតម្លៃនៅស្ថាប័ន ដែលពួកគេនឹងបម្រើការងារក្រោយបញ្ចប់ ការសិក្សា។

បច្ចុប្បន្ន RIA បានចូលរួមចំណែកបង្កើត សេចក្តីប្រកាស និងអនុវត្តអនុក្រឹត្យចំនួន ១៥ ហើយមាន ក្រសួងចំនួន ៤ រួមមានក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងក្រសួង កសិកម្ម បាននឹងកំពុងចូលរួមអនុវត្តគម្រោង RIA ហើយក៏ទទួលបានលទ្ធផលល្អ និងកាត់បន្ថយផល អវិជ្ជមានបានច្រើន។ បើតាមឯកឧត្តម **ឃឹម ណុលសន** គម្រោង RIA នឹងពង្រីកវិសាលភាពរបស់ខ្លួនទៅ តាមបណ្តាក្រសួងមួយចំនួនទៀត ទៅតាមដំណាក់កាល និងថវិកាជំនួយរបស់ ADB។ ការអនុវត្តគម្រោងនេះ ក៏មានផលលំបាកមួយចំនួនផងដែរ ជាមួយការខ្វះខាតលើធនធានមនុស្ស និងមួយផ្នែកទៀតគឺថវិកា។ ហើយ ជាទិសដៅទៅថ្ងៃអនាគត ឯកឧត្តម ចង់សុំជាគោលការណ៍ពីរាជរដ្ឋាភិបាលធ្វើការណែនាំឲ្យក្រសួងទាំងអស់ អនុវត្តគម្រោង RIA ហើយខាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាអ្នកបណ្តុះបណ្តាល និងចូលរួម សហការគាំទ្រជារៀងរហូត។

ឯកឧត្តម ក៏បានអំពាវនាវក្រសួងទាំងអស់ មានមន្ត្រីគម្រោង RIA នៅតាមបណ្តាក្រសួង ដើម្បីធ្វើការ សិក្សា និងវាយតម្លៃលើផលប៉ះពាល់ឲ្យបានកាន់តែច្រើន និងស៊ីជម្រៅលើលិខិតបទដ្ឋានគតិយុត្ត ឬមុនចេញ បញ្ញត្តិកម្មអ្វីមួយ ធ្វើ យ៉ាងណាកាត់បន្ថយផលអវិជ្ជមានឲ្យបានខ្ពស់៕

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡៃន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ចាន់ តិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង វត្តមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ឆារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត ភក្តដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in